06 DEC 2013 H16:30-3032

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
លេខ :...៣៧៤...អ.ជ.ប.ជ.អ.

ភ្នំពេញ, ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ : របាយការណ៍ការងារសំខាន់ៗរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូនសម្តេចមេត្តាជ្រាបនូវសកម្មភាពការងារសំខាន់ៗរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដូចខាងក្រោមនេះ ៖

-**ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២៣ វិច្ឆិកា ២០១៣** : ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំគណៈប្រតិភូចូលរួមសមាជអន្តរជាតិតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី ១១ (ICAAP ll) នៅទីក្រុងបាងកកប្រទេសថៃ ដែលក្នុងនោះ មានគណៈប្រតិភូមកពីប្រទេសនៅក្នុងតំបន់ចំនួន ៨០ ប្រទេស ដោយមានសមាជិកចូលរួមទាំងអស់ប្រមាណ ៣.៩០០នាក់ ។ គណៈប្រតិភូកម្ពុជាទាំងអស់ រួមទាំងតំណាងក្រសួងពាក់ព័ន្ធ តំណាងអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ រួមទាំងអស់ ៨០នាក់ ។ គណៈប្រតិភូ កម្ពុជា បានធ្វើបទបង្ហាញផ្ទាល់មាត់ចំនួន ១៧ លើក និង បទបង្ហាញជាផ្ទាំងក្រដាសចំនួន ២៣ ។ ជាទូទៅ វាគ្មិនសំខាន់ៗនៃអង្គសមាជ បានលើកយកករណីប្រទេសកម្ពុជា ជាគំរូក្នុងការប្រយុទ្ធនឹងជំងឺ អេដស៍ ក្នុងនោះ មានលោកប្រធានាធិបតីនៃប្រទេស Fiji លោក Steve Kraus នាយកប្រតិបត្តិប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការ UNAIDS ។ ដោយឡែក ខ្ញុំបាទប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជួបសន្ទនាជាមួយលោកប្រធានាធិបតីនៃប្រទេស Fiji លោក Steve Kraus លោក Prasada Rao បេសកជនពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិ ទទួលបន្ទុកប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក និង ជាមួយអគ្គនាយកសុខាភិបាល តំណាងរដ្ឋមន្ត្រីសុខាភិបាលនៃប្រទេសថៃ ។ ជាមួយនេះ ស្ថានទូតអូស្ត្រាលីប្រចាំប្រទេសថៃ ក៏បានរៀបចំពិធីបដិសណ្ឋារកិច្ចទទួលប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍របស់កម្ពុជា ជាមួយនឹងថ្នាក់ដឹកនាំនៃអង្គការសហប្រជាជាតិ និង ជាមួយលោកអគ្គរដ្ឋទូតរបស់អូស្ត្រាលី ទទួលបន្ទុកការងារអេដស៍ ដែលមានភារកិច្ចរៀបចំសន្និបាតពិភពលោកស្តីពីអេដស៍ (World AIDS 2014) នៅទីក្រុង Melbourne ប្រទេសអូស្ត្រាលី នៅឆ្នាំ ២០១៤ ខាងមុខនេះ ។

-**នៅថ្ងៃទី ២៧ វិច្ឆិកា ២០១៣** : ខ្ញុំបាទបានបើកអង្គប្រជុំថ្នាក់ដឹកនាំថ្មីទាំងអស់ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីប្រកាសចូលកាន់តំណែងរបស់ថ្នាក់ដឹកនាំទាំងនោះផង និង សំណេះសំណាលអំពីការងារថ្មី និង គោលនយោបាយប្រយុទ្ធនឹងជំងឺអេដស៍ផង ។ ឯកឧត្តម **ម៉ម ប៊ុនហោ** អនុប្រធានទី ១ បានចូលរួមផ្តល់មតិល្អៗមួយចំនួនពាក់ព័ន្ធផែនការការងារ និង សហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និង អាជ្ញាធរអេដស៍ និង គោលនយោបាយសម្រាប់យកមកអនុវត្តនាពេលខាងមុខ ។

-**នៅថ្ងៃទី ២៨ វិច្ឆិកា ២០១៣** : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានបើកអង្គប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលជាអង្គប្រជុំនៃក្រុមប្រឹក្សាគោលនយោបាយ ដោយមានការចូលរួមពីសមាជិកតំណាងក្រសួងទាំងអស់មានចំនួន ៥៨ នាក់ និង សមាជិកតំណាងរាជធានី-ខេត្ត ទាំងអស់ចំនួន ៣១ នាក់ ។ ដោយឡែក សមាជិកតំណាងខេត្តបាត់ដំបង និង ខេត្តសៀមរាប មិនបានចូលរួមទេ ។ អង្គប្រជុំនេះ មានគោលដៅបង្ហាញពីគំរូក្របខ័ណ្ឌវិនិយោគ (Model Frame work Investment) សម្រាប់ឆ្នាំខាងមុខដែលអ្នកផ្តល់ជំនួយមូលនិធិសកល (Global Funds) តម្រូវឲ្យធ្វើសម្រាប់ឆ្នាំ ២០១៤-២០១៥ ។ អង្គប្រជុំបានទទួលយកគោលនយោបាយដែលត្រូវអនុវត្ត ដើម្បីសម្រេចគោលដៅបីសូន្យគឺ ៖ សូន្យការឆ្លងថ្មី សូន្យការរើសអើង និង សូន្យគ្មានការស្លាប់ដោយមេរោគអេដស៍នៅឆ្នាំ ២០១៥ និង ឆ្នាំ ២០២០ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមសម្តេចតេជោ មេត្តាជ្រាបសេចក្តីរាយការណ៍ជូនដ៏ខ្ពង់ខ្ពស់ ។

សូមសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ទេសរដ្ឋមន្ត្រី ឧទ្ទុលបត្តុកបេសកកម្មពិសេស
និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង ម៉ូលី